**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍
## កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមិថុនា ឆ្នាំ២០២២
## ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី

១)- **ថ្ងៃ ខែ ឆ្នាំ៖** នាព្រឹកថ្ងៃចន្ទ ៦កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២។

២)- **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣)- ប្រធាន និងសមាសភាពចូលរួម ៖

- ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ឯកឧត្តម លោកជំទាវ ជាអនុប្រធាន ទីប្រឹក្សា នាយក-នាយករងខុទ្ទកាល័យ អគ្គលេខាធិការ អគ្គលេខាធិការរង ជំនួយការ ប្រធាននាយកដ្ឋាន នៅក្នុងសាលប្រជុំ "ខ" ។
- លោក អ្នកស្រី អ្នកនាងកញ្ញា អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុការិយាល័យ ព្រមទាំងមន្ត្រីនៃ អ.ជ.ប.ជ.អ ចូលរួមតាមបណ្តាញវីដេអូ កម្មវិធី Zoom។

៤)- របៀបវារៈ ៖

- បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២២ ដោយឯកឧត្តម **ឈឹម ឃិនដារ៉េត**។
- បទបង្ហាញ ស្តីពីកាលវិភាគសម្រាប់ឆ្នាំ២០២២ ដោយឯកឧត្តម **ទា ផលា**។
- មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី
- កិច្ចការផ្សេងៗ។

៥)- លទ្ធផល ៖

១). **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

ក- សកម្មភាពការងារដែលសម្រេចបាន ៖

- បានប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ពិនិត្យវឌ្ឍនភាពការងារ និងដាក់ទិសដៅ។

- ដឹកនាំកិច្ចប្រជុំមន្ត្រីអគ្គលេខាធិការដ្ឋានពិនិត្យការងារត្រៀមរៀបចំកិច្ចប្រជុំពេញអង្គលើកទី១។
- បានរៀបចំសិក្ខាសាលាប្រចាំឆ្នាំចែករំលែកបទពិសោធន៍ស្តីពីសមាហរណកម្មសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍឃុំ-សង្កាត់។
- ប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ ពិនិត្យ ពិភាក្សា និងឯកភាពលើរបាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ដឹកនាំកិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងផែនការថវិកាឆ្នាំ២០២៣ បានបញ្ជូនទៅក្រសួងសុខាភិបាល។
- រៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិស ក្នុងការដាក់បញ្ចូលការងារអេដស៍ទៅក្នុងផែនការ៣ឆ្នាំរំកិល ដល់ថ្នាក់ឃុំ សង្កាត់
- បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងពីសមាហរណកម្មសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- បានរៀបចំសុន្ទរកថាបើក និងសុន្ទរកថាបិទជូន ឯកឧត្តមទេសរដ្ឋមន្ត្រី សម្រាប់ថ្លែងក្នុងកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២។
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ. លើកទី១ ឆ្នាំ២០២២។
- បានរៀបចំលិខិតសំណើសុំអន្តរាគមន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ថវិកាចំនួន ៦០.០០០.០០០រៀល ជូនខេត្តចំនួន១១។

**ខ- បញ្ហាប្រឈម ៖**

កង្វះថវិកាសម្រាប់ដំណើរការកិច្ចប្រជុំការបង្កើតក្រុមការងាររៀបចំ ត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣។

**គ- ទិសដៅអនុវត្តបន្ត៖**

- បន្តអនុវត្តសកម្មភាពតាមផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ឆ្នាំ២០២២។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ តាមបណ្តារាជធានី ខេត្តគោលដៅ។
- បន្តសហការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តារាជធានី ខេត្តគោលដៅ។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ. លើកទី៧ លើរបៀបវារៈ "យន្តការពង្រីកតំបន់គ្របដណ្តប់និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាប្រើប្រាស់វិធីលេបថ្នាំបង្ការទុកជាមុន នៅពេលប្រព្រឹត្តប្រឈមនឹងការចម្លងមេរោគអេដស៍ (Pre-exposure prophylaxis, PrEP) ដល់ប្រជាជនគន្លឹះ"។
- រៀបចំលិខិតជូនគណៈរដ្ឋមន្ត្រី សំណើសុំរៀបចំអនុក្រឹត្យស្តីពីការប្រុងប្រយ័ត្នជាសកល ចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។
- បន្តធ្វើការងារជាមួយអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ថវិកាជូនខេត្តទាំង១១។

៣). **បទបង្ហាញ ស្តីពីលទ្ធផលនៃការប៉ាន់ស្មាន ថ្នាក់ ក្រោមជាតិ និងការឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ដោយ ឯកឧត្តម ទា ផលា**

- ការធ្លាក់ចុះនៃករណីឆ្លងថ្មីពី២១០០នៅឆ្នាំ២០១០ ដែលរំពឹងថានឹងចុះដល់៥២០ករណីនៅឆ្នាំ២០២០ នោះគឺបានកើនដល់១១០០ករណីឯនោះ។
- កង្វះថវិកាសម្រាប់ការបង្ការ ខណៈពេលដែលមូលនិធិក្នុងស្រុកបានគ្រោងធ្វើអោយកើនឡើងពី៣៣-៥០%
- កំណត់តួនាទីភារកិច្ចស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធជាតិឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាពហុវិស័យ (Country System to Multi-Sectoral HIV Response) ។
- និន្នាការហិរញ្ញប្បទានពីខាងក្រៅនឹងបន្តធ្លាក់ចុះជាបន្តបន្ទាប់។ រាជរដ្ឋាភិបាលបានតាំងចិត្តបង្កើនហិរញ្ញប្បទានដល់៥០ %នៃការចំណាយលើមេរោគអេដស៍នៅឆ្នាំ២០២៣ និងគួរត្រៀមបែងចែកចំណែកថវិកានេះដល់អង្គការសង្គមស៊ីវិល សម្រាប់ការផ្តល់សេវាឆ្លើយតបនឹងមេរោគអេដស៍ចាំបាច់ផងដែរ។
- មានគម្រោងពង្រីកសេវាប្រើប្រាស់ PrEP (បច្ចុប្បន្នមាន១០ខេត្ត) ទៅខេត្តផ្សេងៗទៀតឱ្យបានទូលំទូលាយ។
- ក្រុមការងារយុទ្ធសាស្ត្រនីមួយៗ ត្រូវមានផែនការសកម្មភាព និងពេលវេលាច្បាស់លាស់ ដែល អ.ជ.ប.ជ.អ ដឹកនាំ គ្រប់គ្រង និងសម្របសម្រួល ជាពិសេសការកំណត់ទិសដៅអាទិភាពឱ្យបានទាន់ពេលវេលា។
- លទ្ធផលការងារហ្វឹកហ្វឺនឆ្លើយតបនឹងមេរោគអេដស៍តាមរយៈផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងផែនការវិនិយោគឃុំ សង្កាត់ (CDP/ICP) មានឃុំចំនួន ៧៧ បានបណ្តុះបណ្តាល និងឃុំ សង្កាត់ ចំនួន៩បានបញ្ចូលថវិកាសម្រាប់ការឆ្លើយតបនឹងជំងឺអេដស៍។
- អង្គការសង្គមស៊ីវិល (CSOs) មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ យុទ្ធសាស្ត្របង្ការ ធ្វើតេស្តឈាមរកមេរោគអេដស៍ គ្រប់ច្រកល្ហក គ្រប់ទីកន្លែង គ្រប់ពេលវេលា ដែលអ្នកផ្តល់សេវាសាធារណៈពិបាកទៅដល់។
- បន្តជំរុញអនុវត្ត*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* ( Fast Track City) ឱ្យបានទូលំទូលាយ។
- តួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺទទួលខុសត្រូវធំទូលាយ និងពហុវិស័យ មានភារកិច្ចត្រួតពិនិត្យ វាយតម្លៃ សម្របសម្រួល និងណែនាំអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។
- សារផ្សព្វផ្សាយអប់រំ ស្តីពីវិធានការបង្ការការចំលងមេរោគអេដស៍ ពិសេសសារជំរុញការប្រើ PreP សម្រាប់ក្រុមបុរសរួមភេទជាមួយបុរស។

៤). **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

ឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

- អបអរសាទរចំពោះលទ្ធផលអង្គប្រជុំក្រុមប្រឹក្សាបច្ចេកទេស។
- កិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២ នេះរៀបចំបានល្អ ចាត់ចែងទទួលភ្ញៀវ និងនាំភ្ញៀវចូលកន្លែងអង្គុយបានល្អ និងបានដាក់ចេញនូវសេចក្តីសម្រេចចិត្តជាច្រើនចំណុច។
- កិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២២ គួរពិចារណារៀបចំធ្វើនៅខេត្តណាមួយ។
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី មានការផ្លាស់ប្តូរមតិយ៉ាងផុលផុស។

- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី មានការផ្លាស់ប្តូរមតិយ៉ាងផុលផុស។
- ការរៀបចំឯកសារបានល្អ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ហើយបានទាន់ពេលវេលា។
- កោតសរសើរដល់គ្រប់ស្ថាប័នទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញក្រុមប្រជាជនគន្លឹះ ដែលបានប្រឹងប្រែងបន្តចូលរួមការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

## ការផ្តល់អនុសាសន៍

១- អគ្គលេខាធិការ ពង្រាងនូវរបៀបវារៈនៃអង្គប្រជុំក្រុមប្រឹក្សាបច្ចេកទេស ជូនកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត ពិនិត្យ និងផ្តល់មតិ មុនកិច្ចប្រជុំប្រចាំខែ។

២- អគ្គលេខាធិការ ត្រូវធ្វើរបាយការណ៍រាល់កិច្ចប្រជុំទាំងអស់ជាភាសាខ្មែរ និងភាសាអង់គ្លេស ចាប់ពីពេលនេះតទៅ។

៣- កិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត ត្រូវធ្វើនៅថ្ងៃទី១១ ខែមិថុនា ដើម្បីពិនិត្យលើរបៀបវារៈកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងរៀបចំឯកសារស្តីពីការពង្រឹងប្រព័ន្ធជាតិឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាពហុវិស័យ (Country System to Multi-Sectoral HIV Response)។

៤- អគ្គលេខាធិការ ដឹកនាំប្រជុំក្រុមប្រឹក្សាបច្ចេកទេស ដោយយោងតាមរបៀបវារៈដែលបានដាក់ជូន និងសម្រេចក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត។

៥- ឯកឧត្តមអគ្គលេខាធិការ ត្រៀមរៀបចំកម្មវិធីបទសម្ភាសន៍របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ជាមួយទូរទស្សន៍ ដើម្បីលើកអំពីការរាលដាលនៃមេរោគអេដស៍ និងការកង្វល់របស់ អ.ជ.ប.ជ.អ ។

៦- គណៈកម្មាធិការរៀបចំសារអប់រំ (IEC) គួរតែផ្តោតសំខាន់លើសកម្មភាពជាក់ស្តែងដែលងាយស្រួលសម្រាប់ក្រុមគោលដៅ បង្ហាញហានីភ័យនៃការឆ្លងមេរោគអេដស៍ ផលវិបាកនៃការឆ្លងមេរោគអេដស៍លើសុខភាព ការរំខានដល់ប្រសិទ្ធភាពបំពេញការងារ និងផលប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ។

៧- ណែនាំពីទីតាំងផ្តល់សេវាប្រើប្រាស់វិធីលេបថ្នាំបង្ការទុកជាមុន នៅពេលប្រព្រឹត្តប្រឈម នឹងកាចម្លងមេរោគអេដស៍) Pre-exposure prophylaxis: PrEP) ដល់ប្រជាជនគន្លឹះ។

៨- អញ្ជើញមន្ត្រីបច្ចេកទេសក្រសួងយុត្តិធម៌ ឱ្យមកជួយពិនិត្យលើខ្លឹមសារនៃអនុក្រឹត្យស្តីពីការប្រុងប្រយ័ត្នជាសកលនៃការចម្លងមេរោគអេដស៍ មុននឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី។

៩- បន្តជំរុញប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត រៀបចំផែនការសកម្មភាព និងគម្រោងថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ស្របតាមអាណត្តិការងារក្នុងផែនការថវិកាឆ្នាំ២០២៣។

១០-បន្តជំរុញអនុវត្តគោលនយោបាយស្រោមអនាម័យ១០០ភាគរយ នៅតាមកន្លែងផ្សេងៗ ដូចជាសណ្ឋាគារ បៀរហ្គាដិន ខារ៉ាអូខេ និងទីកន្លែងកម្សាន្តនានា។

១១-បន្តជំរុញការផ្តល់សេវាបង្ការ ការពារ ថែទាំ កាត់បន្ថយការចម្លងមេរោគអេដស៍ពីមាតាទៅទារកឱ្យបានតាមគោលដៅកំណត់។

១២- បន្តស្វែងរក និងបញ្ចុះបញ្ចូលឱ្យអ្នកផ្ទុកមេរោគអេដស៍ ដែលមិនទាន់មកទទួលសេវាព្យាបាល ឱ្យមកទទួលធ្វើតេស្តរកមេរោគអេដស៍ ដើម្បីទទួលបានសេវាថែទាំ និងព្យាបាលឱ្យបានទាន់ពេល។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យចំទិសដៅ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមយន្តការយុទ្ធសាស្ត្រនីមួយៗឱ្យកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:១៧នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

ស៊ុត_ផលផាន់

បានឃើញ និងឯកភាព

ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

**ប្រធានស្តីទី**

គង់_វដ្ឋា